# ១០. រឿង តម្លង់៧សន្តាន

កាលពីព្រេងនាយ មានបុរសប្ដីប្រពន្ធ នាំគ្នាទៅសួរបងប្អូននៅភូមិត្រៃសណ្ដែកដើរ ៗ ទៅប្រទះនឹងអាតម្លង់ ៧ សន្តាន កំពុងតែទឹមគោភ្ជួរស្រែ ។ បុរសប្ដីប្រពន្ធនោះ សួរថា «អ្នកអើយអ្នក! ផ្លូវណាកាត់ត្រង់ទៅលើភូមិព្រៃសណ្ដែក ត្បិតខ្ញុំខានមកយូរឆ្នាំហើយ មិនដឹងជាផ្លូវណាគាត់ទៅឲ្យត្រង់ ?» ។

កូនក្រោលបង្គោលស្នឹង អាក្រហមមួយនេះ ម្ដាយក្មេកគាត់ចែក ឯអាស្មែងកន្ទែកឱអញគាត់ឲ្យ អញមិនលួចគោរបស់អាណាមកទឹមទេ» ។

ឯបុរសប្ដីប្រពន្ធដែលសួរផ្លូវនោះ ឮហើយនិយាយគ្នាថា «អ្នកនេះ យើងសួរផ្លូវគាត់ ៗនិយាយពីគោ ហើយស្ដីគំរោះគំរើយឲ្យយើងផង ណ្ដើយគេហ៍! យើងកុំខ្ចីសួរវា យូរឆាប់គង់តែនឹងទៅដល់ផ្ទះបងប្អូនមិនខាន» ហើយក៏បណ្ដើរគ្នាហួសទៅ ។ ឯអាតម្លង់៧ សន្តាននោះ ក៏ខំភ្ជួរស្រែមិនឈប់ ដល់ពេលថ្ងៃជិតត្រង់ មេតម្លង់ជាប្រពន្ធក៏ទូលបាយទៅឲ្យប្ដីបរិភោគ លុះទៅដល់ក៏ដាក់ល្អីបាយក្រោយម្លប់ឈើ នៅភ្លឺស្រែ ។ ប្ដីឃើញប្រពន្ធយកបាយមកឲ្យ ក៏ឈប់ភ្ជួរស្រែ បរិភោគបាយ និយាយទាំងខឹងប្រាប់ប្រពន្ធថា «មានបុរសប្ដីប្រពន្ធបណ្ដើរគ្នាមកពីណាចោទប្រកាន់ថា អញលួចគោវា ឯគោ ១ នឹមនេះ ប្រាកដជាម៉ែឪឯងចែកមក» ។ ប្រពន្ធឃើញមាត់ប្ដីនិយាយម្ហូបៗ នឹកស្មានថាស្ដីឲ្យខ្លួនស្រាប់តែខឹង ហើយឆ្លើយតបទៅវិញថា «អញគិតថាប្ដីមកភ្ជួរស្រែទាន់ថ្ងៃត្រង់ ខំប្រញាប់ប្រញាល់ទូលបាយមកឲ្យស៊ី ឥឡូវទៅជាថា ឯងមានសហាយ អញសហាយនឹងឈ្មោះអាណា គាត់រកមុខឲ្យឃើញ» ។ ឯប្ដីមិនទាល់តែពមបាយ អស់មួយកូនល្អី ប្រពន្ធថាអ្វីក៏មិនឮផង ។ លុះប្ដីបរិភោគរួច ប្រពន្ធកន្ត្រាក់យកល្អី ។ ប្ដីសួរថា «ឯងមានការអ្វីឯផ្ទះបានជាប្រញាប់ម្ល៉េះ?» ប្រពន្ធថា «អញមុខជាប្រាប់ម៉ែឪអញមិនខាន» ហើយកណ្ដៀតល្អីត្រឡប់ទៅដល់ផ្ទះ ជួបនឹងម្ដាយ និយាយទាំងខឹងមុខក្រហមប្រាប់ម្ដាយថា «កូនប្រសាម៉ែឯងវាល្អហើយ! ខ្ញុំទូលបាយទៅឲ្យស៊ី ដាក់ល្អីស្ទើរតែមិនទាន់ វាស្ដីឲ្យខ្ញុំថាមានសហាយ» ។

ចំណែកម្ដាយនោះ ខឹងញ័រឡើងថា «ហាងឯង ដូច្នេះទេតើ បានជាមុខក្រហម អញថាកូនថាចៅ បានជាចាំផ្ទះឲ្យវា ឥឡូវវាថាឯងលួចថ្នាំវាយកទៅដូរដូង មេអន្តរធានឯងក្រោយៗ កុំនិយាយដូច្នេះ មិនត្រូវទេ សូម្បីតែថ្នាំ១ផ្នុក ក៏អញមិនលួចយកផង បើទុកជាអញយកមែន ម្ដាយនឹងកូនមិនត្រូវហាងឯងពោលឲ្យអញខ្មាសគេទ ចាំឪហាងឯងមកអញប្រាប់ឲ្យជេរវាយប្រដៅហាងឯងមិនខាន» ។

លុះយូរបន្តិច ប្ដីមកពីកាប់បង្គោលធ្វើរបងបង្ការមិនឲ្យគោក្របីចូលស៊ីសំណាបសន្ទូង ប្រពន្ធនិយាយប្រាប់ប្ដីថា «កូនស្រីយើងវាយកបាយទៅឲ្យប្ដី ខ្ញុំចាំផ្ទះឲ្យវា លុះមកវិញ វាថាខ្ញុំជាម្ដាយលួចថ្នាំវាដូរដូង ខ្ញុំខឹងណាស់» ។

ប្ដីស្ដាប់មិនឮ ខឹងនឹងប្រពន្ធក៏ជេរថា «មេចោរគ្រហរ! ហាងឯងប្រចណ្ឌអញអីម្ល៉េះ ! អញមានស្លៀកពាក់តែងតួដើរលេងចង់ស្រីឯណា អញទៅកាប់ឈើធ្វើបង្គោលរបងទេតើ! អញអត់តែម្ដងនេះ ក្រោយៗបើហាងឯងនៅតែស្ដីប្រចណ្ឌអញទៀត មុខជាអញធាក់ឲ្យដួលទាំងជំហរមិនខាន» ហាមប្រពន្ធហើយ បរិភោគបាយ រួចទៅចងសន្ទូចបានត្រី ត្រឡប់មកផ្ទះវិញ ។ វេលាថ្ងៃល្ងាច ប្រពន្ធក៏ធ្វើត្រីស្ងួតអាំងឲ្យប្ដីបរិភោគខ្លះ រំលែកទុកព្រឹកខ្លះ ដើម្បីនឹងធ្វើសម្រាប់យកទៅប្រគេនលោកកូនឯវត្ត និងកូនប្រុសតូចម្នាក់ឲ្យនៅរៀនអក្សរជាមួយនឹងលោកបងនោះ ។

លុះព្រឹកឡើង ម្ដាយនោះដាំបាយដួសដាក់ចាន មានម្ហូបពីល្ងាចស្រាប់ ទូលយកទៅដល់កុដិប្រគេនលោកកូន ហើយនិយាយថា « ខ្ញុំព្រះករុណារលឹកលោកកូនណាស់! មួយទៀតប្អូនតូចវារៀនអក្សរគ្រាន់បើទេ?» ។ លោកកូននោះប្រាប់ថា «ចម្រើនពរញោម! អាត្មាសព្វថ្ងៃនេះ កំពុងស្រឡាញ់សីលផ្នួសណាស់, អាត្មាមិនសឹកទេ» ។ ម្ដាយក៏ហៅកូនតូចដែលនៅបម្រើបងនោះថា «អានាង! លាលោកបងទៅផ្ទះនឹងម្ដាយបានមួយថ្ងៃសិន ត្បិតឪពុកឯងរពឹកណាស់» ។ កូនតូចឆ្លើយប្រាប់ម្ដាយថា «ត្រីងៀតលោកបង នៅពីរកន្ទុយទុកក្នុងកុដិ, ពេលល្ងាច ខ្ញុំយកពីរចម្រៀកដុតស៊ីបាយ ដែលសល់ពីលោកឆាន់ពេលព្រឹកនោះ» ។

ឯលោកសង្ឃ ដែលគង់នៅជិតកុដិទាំងប៉ុន្មាន បានឮម្ដាយនឹងកូននិយាយតែដោយខ្លួន មិនទទួលសម្រុងគ្នាដូច្នេះ លោកទាំងអស់ទប់ពុំបាន ក៏សើចទ្រហឹងអឺងអាប់ ។ សិកានោះ ក៏សំពះលាលោកកូនត្រឡប់មកដល់ផ្ទះវិញ ហើយលុតជង្គង់ជូនបុណ្យប្ដីថា «ខ្ញុំជូនបុណ្យអ្នកផង» ។ ប្ដីឆ្លើយថា «អើ! អញឃើញបាយសម្លខអាំង ព្យួរទុកនៅសង្រែក អញស៊ីអស់ទៅហើយ» ។ ប្រពន្ធក៏មើលមុខប្ដី ។ មើលមុខប្រពន្ធ ប៉ប្រិចភ្នែកម៉ក់ៗ ធ្វើវាហឺតែដោយខ្លួន ។ លុះយូរបន្តិច ស្រាប់តែប្អូនស្រីបង្កើតខាងប្ដី នៅភូមិដទៃឆ្ងាយមកដល់ បានផ្លែពង្រមួយផ្តិលនិងស្លឹកប្រស់ស្វាមួយសំណុំមកផ្ញើបង និយាយសួរបងថា «បងបានភ្ជួររាស់ដកស្ទូងបានស្រែប៉ុន្មានហើយ?» ។ បងទាំងប្ដីប្រពន្ធឆ្លើយប្រាប់ទៅប្អូនស្រីវិញថា «អើហាង! ល្មមទុកដាក់ឲ្យវាមានប្ដីទៅចុះ តែហាងមើលកុំឲ្យតែចេះលេងបៀជឹកស្រាជក់អាភៀន» ។

ប្អូនស្រីស្ដាប់មិនឮទៀត ក៏ប្រាប់ទៅបងទាំងពីរនាក់ថា «ខ្ញុំស្ដាយត្រឡាចខ្ញុំមួយទ្រើងណាស់ កំពុងតែផ្កាក្បិបតូច ៗ ស្រាប់តែមេជ្រូកវាទៅឈ្មុសគល់ដាច់ងាប់អស់» ។ បងទាំងពីរនាក់ថា «អើហាង! ល្មមទៅផ្ទះក៏ទៅចុះ ល្ងាចណាស់ហើយ ក្រែងកូនវាយំរក» ។ ប្អូនស្រីនោះ ក៏ត្រឡប់ទៅផ្ទះវិញ ។

ព្រោះអ្នកទាំង ៧ នាក់ គឺបុរស-ស្ត្រី ប្ដីប្រពន្ធ, ម្ដាយឪពុក, លោកភិក្ខុ-កុមារជាកូននិងប្អូនស្រី សុទ្ធតែថ្លង់និយាយមិនចុះសម្រុងគ្នា បានជារឿងនេះគេហៅថា រឿងតម្លង់៧សន្តាន ។

**ស្ដាប់មិនជាក់ កុំអាលញាក់ចិញ្ចើម**